# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

៣៚៣៚៣៚

# អនុស្សារណៈយោគយល់

## មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបន្ទាយមានជ័យ

## និង

## អង្គការអភិវឌ្ឍន៍សហគមន៍ជនបទ និងបរិស្ថាន (RCEDO) និង

## អង្គការអភិវឌ្ឍន៍សង្គម បរិស្ថាន និង កសិកម្ម (SEADO)

### ១.សេចក្តីផ្តើម៖

អនុស្សារណៈយោគយល់នេះ គឺដើម្បីបង្កើតអោយមាន កិច្ចសហប្រតិបត្តិការរវាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយ **អង្គការអភិវឌ្ឍន៍សហគមន៍ជនបទ និងបរិស្ថាន (RCEDO) និង អង្គការ អភិវឌ្ឍន៍សង្គម បរិស្ថាន និង កសិកម្ម (SEADO)** តាមរយៈ **ការអនុវត្តគម្រោងកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយសហគមន៍ ដំហ៊ាន ២ ខែមេសា ២០១៨ ដល់ ខែមិនា ២០២១។**

គោលបំណង គឺ ចូលរួមចំណែកធ្វើឲ្យប្រជាពលរដ្ឋក្នុងសហគមន៍កាន់តែមានលទ្ធភាពទទួលនូវការលើកកម្ពស់ជីវភាពរស់នៅតាមរយៈការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយធម្មជាតិ ដោយការដាំដុះដំណាំស្រូវ បន្លែ និងការចិញ្ចឹមសត្វ ដែលបន្សុាំនឹងការប្រែប្រួលអាកាសធាតុជាពិសេសគ្រោះមហន្តរាយទឹកជំនន់ និង រាំងស្ងួត ។ កិច្ចសហប្រតិបត្តិការនេះ នឹងធ្វើអោយការអនុវត្តគម្រោង(CBDRR-II) កាន់តែមានប្រសិទ្ធភាព និង សំរេចបាននូវគោលដៅរួមរបស់គម្រោង ដែលស្របតាមគោលនយោបាយ និងយុទ្ធសាស្រ្ត របស់រាជរដ្ឋាភិបាល ស្តីពីការបញ្ជ្រាបដោយប្រសិទ្ធភាពនូវការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយទៅក្នុងដំណើរការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចគ្រប់កម្រិត។

### ២. គោលបំណង នៃកិច្ចសហប្រតិបត្តិការ៖

១-ពង្រឹងកិច្ចសហការជាដៃគូ ក្នុងការអនុវត្តគម្រោងកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយសហគមន៍ ។

២-ផ្តល់ជំនួយបច្ចេកទេស និងការអនុវត្តបង្ហាញជាក់ស្តែងដល់កសិករ អំពីការដាំដុះដំណាំស្រូវដែលបន្សុាំនឹងការប្រែប្រួលអាកាសធាតុ ការដាំបន្លែសេរីរាង្គ និងការចិញ្ចឹមសត្វដែលមានភាពធន់នឹងអាកាសធាតុ ។

៣-ជំរុញ និង សម្របសម្រួលក្នុងការបង្កើតសហគមន៍ស្រូវ បន្លែសិរីរាង្គ និងសត្វដែលបន្សុាំនឹងការប្រែប្រួលអាកាសធាតុ។

៤-ចូលរួមត្រួតពិនិត្យ តាមដាន និង ផ្តល់អនុសាសន៍ដើម្បីអោយសកម្មភាពគម្រោងដែលទាក់ទងវិស័យកសិកម្មកាន់តែប្រសើរឡើង ។

### ៣. លទ្ធផលរំពឹងទុកនៃកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តគម្រោង៖